THE STATE EDUCATION DEPARTMENT /
THE UNIVERSITY OF THE STATE OF NEW YORK / ALBANY, NY 12234

**Lissette Colon-Collins, Assistant Commissioner | Office of Bilingual Education and World Languages**

55 Hanson Place, Room 594
Brooklyn, New York 11217
Tel: 718-722-2445 Fax: 718-722-2459

89 Washington Avenue, Room 528EB
Albany, New York 12234
Tel: 518-474-8775 Fax: 518-474-7948

# សិទ្ធិ មូលដ្ឋានរបស់មាតាបិតាសិស្ស សម្រាប់សិស្សសិក្សាភាសាអង់គ្លេសនៅរដ្ឋញ៉ូយ៉ក

បទប្បញ្ញត្តិស្នងការផ្នែកទី154 នៃក្រសួងអប់រំរដ្ឋញ៉ូយ៉ក (NYSED- New York State Education Department) ផ្តល់ឲ្យអ្នកដែលជាមាតាបិតា/អាណាព្យាបាលរបស់សិស្សជាអ្នកសិក្សាភាសាអង់គ្លេស (ELLs) នូវសិទ្ធិមួយចំនួនដូចខាងក្រោម ៖

1. សិទ្ធិសម្រាប់កូនរបស់អ្នកក្នុងដើម្បីទទួលបានការអប់រំសាធារណៈដោយមិនគិតថ្លៃនៅមណ្ឌលសិក្សាស្រុក នៅកន្លែងដែលអ្នករស់នៅ ដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក ឬរបស់កូនរបស់អ្នក (ឧទាហរណ៍ មិនថាសមាជិកគ្រួសាររបស់អ្នកជាពលរដ្ឋសហរដ្ឋអាមេរិក ជាជនអន្តោប្រវេសន៍ ឬគ្មានលិខិតបញ្ជាក់ណាមួយ) និងភាសាដែលអ្នក ឬកូនរបស់អ្នកនិយាយឡើយ ។

2. សិទ្ធិចុះឈ្មោះកូនរបស់អ្នកចូលសាលារៀនដោយមិនតម្រូវឱ្យផ្តល់ព័ត៌មាន ឬក្រដាសស្នាម ដែលអាចបង្ហាញពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក ឬរបស់កូនអ្នកឡើយ ។ សាលាមិនអាចសុំប័ណ្ណ ឬលេខសន្តិសុខសង្គម ទិដ្ឋាការអន្តោប្រវេសន៍ ឬស្ថានភាពទិដ្ឋាការ ឬឯកសារបញ្ជាក់ភាពជាពលរដ្ឋសហរដ្ឋអាមេរិក ឬស្ថានភាពជាពលរដ្ឋសហរដ្ឋអាមេរិករបស់អ្នកឡើយ ។

3. សិទ្ធិក្រោមច្បាប់ ច្បាប់សហព័ន្ធ ក្នុងការទទួលបានអ្នកបកប្រែភាសាផ្ទាល់មាត់/អ្នកបកប្រែភាសាលើក្រដាស សម្រាប់ភាសាដែលអ្នកនិយាយដើម្បីផ្តល់ការបកប្រែដែលសំខាន់ៗពេលអ្នកនិយាយជាមួយមណ្ឌលសិក្សាស្រុក។

4. សិទ្ធិឱ្យកូនរបស់អ្នកចូលរួមក្នុងកម្មវិធី ការសិក្សាពីរភាសា (BE) នៅពេលដែលមានសិស្សកម្រិតបឋម ឬមធ្យមសិក្សាចំនួន 20នាក់ ឬច្រើនជាងនេះ ដែលនិយាយភាសាកំណើត/ភាសានិយាយនៅផ្ទះដូចគ្នា ។ [1]

5. សិទ្ធិទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាភាសាអង់គ្លេស និងភាសាដែលពេញចិត្ត ដែលកូនរបស់អ្នកត្រូវបានកំណត់ថាជា ELLs ហើយត្រូវចាត់ឲ្យចូលរៀនទៅក្នុងកម្មវិធីសិក្សាពីរភាសា ឬ កម្មវិធីភាសាអង់គ្លេសជាភាសាថ្មី (ដែលពីមុនហៅថាកម្មវិធី អង់គ្លេសជាភាសាទីពីរ)។ [2]

6. សិទ្ធិទទួលបានវគ្គអប់រំមានគុណភាពខ្ពស់ ដែលផ្តល់ដោយមណ្ឌលសិក្សាស្រុករបស់អ្នក ដែលផ្តោតបទដ្ឋានការអប់រំរបស់រដ្ឋ ការធ្វើតេស្ត និងក្តីរំពឹងរបស់សាលាសម្រាប់ ELLs ក៏ដូចជាគោលបំណង និងលក្ខខណ្ឌតម្រូវរបស់កម្មវិធីសម្រាប់ការសិក្សាពីរភាសា និងភាសាអង់គ្លេសជាភាសាថ្មី ។ ការបណ្តុះបណ្តាលនេះត្រូវធ្វើឡើងមុនពេលកម្មវិធីប្រឡងចុងក្រោយរបស់សាលា និងត្រូវធ្វើឡើងជាភាសាដែលអ្នកពេញចិត្ត ។

7. សិទ្ធិទទួលបានព័ត៌មានអំពីការអភិវឌ្ឍភាសាអង់គ្លេសរបស់កូនអ្នក និងអំពីការអភិវឌ្ឍភាសាកំណើតរបស់ពួកគេ ក្នុងករណីដែលពួកគេជាសិស្សនៅក្នុងកម្មវិធីការសិក្សាពីរភាសា។

8. សិទ្ធិជួបជាមួយបុគ្គលិកសាលារៀនយ៉ាងតិចចំនួនមួយក្នុងមួយឆ្នាំ បន្ថែមពីការប្រជុំផ្សេងទៀត ដែលជាភាពតម្រូវទូទៅ ដើម្បីពិភាក្សាអំពីការរីកចម្រើនទូទៅលើការសិក្សា និងការវិវត្តន៍ផ្នែកភាសារបស់កូនរបស់អ្នក។

9. សិទ្ធិដាក់កូនរបស់អ្នកឱ្យចូលសិក្សាក្នុងកម្មវិធីសិក្សាពីរភាសា ឬកម្មវិធីភាសាអង់គ្លេសជាភាសាថ្មីក្នុងរវាង 10 ថ្ងៃគិតចាប់ពីថ្ងៃចុះឈ្មោះចូលរៀន និងសិទ្ធិចាកចេញពីកម្មវិធីសិក្សាពីរភាសា ។ ជាកម្រិតអប្បបរមា កូនរបស់អ្នកត្រូវទទួលបានការអប់រំក្នុងកម្មវិធីភាសាអង់គ្លេសជាភាសាថ្មី។

10. សិទ្ធិក្នុងការផ្ទេរកូនរបស់អ្នកទៅសាលារៀនផ្សេងនៅក្នុងមណ្ឌលសិក្សាស្រុករបស់អ្នកដែលមានផ្តល់កម្មវិធីសិក្សាពីរភាសាជាភាសារបស់អ្នក ប្រសិនបើសាលារៀនដើមរបស់កូនអ្នកមិនមានបង្រៀនកម្មវិធីនេះ។

11. សិទ្ធិសម្រាប់កូនរបស់អ្នកក្នុងការទទួលការចូលរួមដោយស្មើភាពគ្នាសម្រាប់កម្មវិធី និងសេវាទាំងអស់ដែលផ្តល់ឱ្យដោយមណ្ឌលសិក្សាស្រុក ស្របតាមអាយុ និងថ្នាក់រៀនរបស់ពួកគេ រួមទាំងសិស្សដែលត្រូវរៀនបញ្ចប់នៅវិទ្យាល័យ និងចំពោះកម្មវិធីសាលាទាំងអស់ដែលមានសម្រាប់សិស្សផ្សេងទៀត។

12. សិទ្ធិសម្រាប់កូនរបស់អ្នកក្នុងការទទួលការអប់រំសំខាន់ៗ និងសិក្សាភាសាអង់គ្លេស និងមុខវិជ្ជាផ្សេងៗ ដូចជាអំណាន/អក្សរសិល្ប៍ គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម នៅក្នុងកម្រិតថ្នាក់ដូចគ្នាជាមួយនឹងក្មេងផ្សេងៗទៀត ។ ក្នុងនាមជាអ្នកមានសិទ្ធិទទួលបានសេវា ELL មិនមែនមានន័យថា សមត្ថភាពរបស់កូនអ្នកក្នុងការទទួលការអប់រំតាមកម្មវិធីសិក្សាស្នូល មានកម្រិតឡើយ ។

13. សិទ្ធិរបស់កូន ក្នុងការចូលរួមបានពេញលេញចំពោះសកម្មភាពសិក្សាបន្ថែម (ក្លឹបសិក្សាក្រោយចប់ម៉ោងរៀន សកម្មភាពកីឡា។ល។) ដោយការចុះក្នុងនាមជាអ្នកមានសិទ្ធិទទួលបានសេវា ELL មិនមែនមានន័យថា សមត្ថភាពកូនអ្នក មានកម្រិតក្នុងការ ចូលរួមក្នុងសកម្មភាពសិក្សាបន្ថែមឡើយ ។

14. សិទ្ធិកូនរបស់អ្នកក្នុងការទទួលបានសេវាគាំទ្រ (ឧទាហរណ៍ សេវាអន្តរាគមន៍ការសិក្សា) ដែលស្របជាមួយផែនការអន្តរាគមន៍ណាមួយដែលមណ្ឌលសិក្សាស្រុកផ្តល់ដល់សិស្សទាំងអស់ ។

15. សិទ្ធិឱ្យកូនរបស់អ្នកបានចូលប្រឡងប្រចាំឆ្នាំ ដើម្បីវាស់ភស្តុងភាពរីកចម្រើនផ្នែកភាសាអង់គ្លេសរបស់ពួកគេ និងដើម្បីទទួលបានព័ត៌មានអំពីលទ្ធផលការសិក្សារបស់កូនអ្នកអំពីការប្រឡង ប្ញករួមទាំងការប្រឡងរបស់ រដ្ឋញ៉ូយ៉កផងដែ។

16. សិទ្ធិឱ្យកូនរបស់អ្នកបន្តចុះឈ្មោះសិក្សាពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងកម្មវិធីសិក្សពីរភាសាឬ ភាសាអង់គ្លេសជាភាសាថ្មីក្នុងពេលដែលពួកគេ ស្ថិតនៅជាសិស្ស ELLs។

17. សិទ្ធិធ្វើការទំនាក់ទំនងមក ការិយាល័យសិក្សាពីរភាសា និងភាសាពិភពលោកនៃក្រសួងអប់រំរដ្ឋញ៉ូយ៉ក ប្រសិនបើសិទ្ធិណាមួយដូចបានរៀបរាប់ខាងលើត្រូវបានរំលោភបំពាន ។

សូមទូរស័ព្ទមក **លេខទាន់ហេតុការណ៍សម្រាប់មាតាបិតាសិស្ស ELL** តាមលេខ **1-800-469-8224** ឬ អ៊ីម៉ែល៖ nysparenthotline@nyu.edu

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ **www.p12.nysed.gov/biling**
ឬសរសេរសំបុត្រទៅកាន់អាសយដ្ឋាន៖

New York State Education Department
Office of Bilingual Education & World Languages
55 Hanson Place, Room 594
Brooklyn, New York 11217

[1] នៅក្រុងញូយ៉ក ដោយអនុលោមទៅតាម អនុក្រិតផ្តល់សេចក្តីយល់ព្រម Aspira  (Aspira Consent Decree) កម្មវិធី BE គឺជាភាពតម្រូវសម្រាប់សិស្សពីថ្នាក់មតេយ្យ ដល់ថ្នាក់ទី 8 ប្រសិនបើមានសិស្សចំនួន 15 ឬច្រើនជាងនេះ រៀននៅថ្នាក់ក្រោមវិទ្យាល័យដែលនិយាយភាសាដូចគ្នា នៅក្នុងកម្រិតថ្នាក់ពីរជាប់ៗគ្នា ។ ប្រសិនបើមិនមានចំនួនសិស្សដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់នៅក្នុងសាលាណាមួយទេ
តែមានសិស្សដែលមានលក្ខណ:សម្បត្តិគ្រប់គ្រាន់នៅក្នុងមណ្ឌលសិក្សាស្រុកដូចគ្នា មណ្ឌលសិក្សាស្រុកនោះត្រូវបើកឲ្យមានកម្មវិធី BE ។

[2] សិស្សជាអ្នកសិក្សាភាសាអង់គ្លស (ELLs) ទាំងអស់ ធ្វើការអភិវឌ្ឍន៍ជំនាញភាសាអង់គ្លេសរបស់ខ្លួនតាមរយ: មុខវិជ្ជា  "អង់គ្លេសជាភាសាថ្មី" ។ លើសពីនេះ សិស្សទាំងអស់ដែលស្ថិតក្នុងកម្មវិធីសិក្សាពីរភាសា ក៏ត្រូវចូលរៀនមុខវិជ្ជា អក្សរសិល្ប៍ជាភាសាកំណើត (Home Language Arts) ផងដែរ ។  ខ្លឹមសារស្នូលតាម     វិស័យ មុខវិជ្ជា (ដូចជា គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម) ដែលត្រូវបង្រៀនសិស្សក្នុងកម្មវិធីសិក្សាពីរភាសា គឺត្រូវបង្រៀន *ទាំង* ភាសាអង់គ្លេស និងភាសាកំណើត (ភាសាប្រើនៅផ្ទះ) របស់ពួកគេផងដែរ ។ ចំពោះសិស្សដែលមិនបានស្ថិតនៅក្នុងកម្មវិធីសិក្សាពីរភាសាទេ  គឺត្រូវរៀនខ្លឹមសារស្នូលនៃវិស័យមុខវិជ្ជា *ជាភាសាអង់គ្លេស ។*